# កម្ពុជាមានក្រុមហ៊ុនរកស៊ីរៀបចំគម្រោងអាពាហ៍ពិពាហ៍



*ភ្ញៀវចូលរួមគម្រោងអាពាហ៍ពិពាហ៍*
*(រូបថត:គីម ប៊ុន)*



*លោកស្រី Eileen Lui និងលោកស្រី Leticia Hsu មានមតិក្នុងពិធីបង្ហាញគម្រោងអាពាហ៍ពិពាហ៍*

**ភ្នំពេញ :** ការតាំងពិព័រណ៍បង្ហាញពីពិធីអាពាហ៍ពិពាហ៍ដែលរៀបចំដោយ The Wedding Planner នៅភោជនីយដ្ឋាន១១២ មានទីតាំងស្ថិតនៅអគារ១អា ផ្លូវ១០២ខាងក្រោយសកលវិទ្យាល័យជាតិគ្រប់គ្រងបានបង្ហាញឱ្យដឹងថា កម្ពុជាមានក្រុមហ៊ុនរកស៊ីរៀបចំគម្រោងអាពាហ៍ពិពាហ៍ គឺផុសចេញពីគំនិតផ្ទាល់របស់បុគ្គលពីររូបគឺ លោកស្រី Eileen Lui និងលោកស្រី Leticia Hsu ។

នៅក្នុងពិធីតាំងបង្ហាញពិព័រណ៍អាពាហ៍ពិពាហ៍ដែលបានធ្វើឡើងនាព្រឹកថ្ងៃទី៨ខែសីហាឆ្នាំ២០០៩ លោកស្រីទាំងពីរបានឱ្យដឹងថា The Wedding Planner បានបង្កើតឡើងនៅប្រទេសម៉ាឡេស៊ី ហើយកម្មវិធីនេះលោកស្រីចង់ឱ្យមានចូលក្នុងទីផ្សារថ្មីមួយទៀតនៅប្រទេសកម្ពុជា ព្រោះលោកស្រីធ្លាប់មានបទពិសោធន៍១៥ឆ្នាំមកហើយ ។

នៅកម្ពុជាពិធីអាពាហ៍ពិពាហ៍មានការពេញនិយមខ្លាំងណាស់នៅរដូវអាពាហ៍ពិពាហ៍ក្នុងមួយថ្ងៃជាមធ្យមមានអ្នករៀបអាពាហ៍ពិពាហ៍ពី៥០ទៅ៦០គូយ៉ាងតិច ។

លោកស្រីទាំងពីរបានបញ្ជាក់ផងដែរថា បច្ចុប្បន្នគម្រោងទាំងនេះបានស្ថិតនៅក្នុងប្រទេសកម្ពុជាហើយ ហើយទីផ្សារទាំងនេះបានបើកចំហសម្រាប់អ្នកដែលត្រូវការ ព្រោះ TWP មានសេវាកម្មគ្រប់ផ្នែកទាំងអស់ ដោយនៅតែរក្សាភ្ជាប់ជាមួយប្រពៃណី និងវប្បធម៌របស់ប្រទេសកម្ពុជា ព្រោះប្រទេសកម្ពុជាជាប្រទេសមួយដែលសម្បូរទៅដោយប្រពៃណី និងវប្បធម៌ដែលធ្វើឱ្យអ្នកស្រីធ្លាក់ក្នុងអន្លង់ស្នេហ៍ ។

ចំពោះទស្សនៈទេសចរណ៍ វិញ TWP បានត្រៀមជាស្រេចនូវកន្លែងអាពាហ៍ពិពាហ៍ ដោយមានការលក់កញ្ចប់រវាងប្រទេសទាំងពីរ គឺសម្រាប់ពលរដ្ឋម៉ាឡេស៊ី ដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា ហើយពលរដ្ឋកម្ពុជាដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសម៉ាឡេស៊ី ។ ត្រង់ចំណុចនេះ TWP នឹងពង្រីកទូទាំងអាស៊ីនិងអឺរ៉ុបនៅថ្ងៃខាងមុខទៀត ។

TWP បានចាប់ផ្តើមប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាជាផ្លូវការនៅថ្ងៃទី១៥ខែមិថុនាឆ្នាំ២០០៩ ហើយនាំមកជាមួយពួកគេនូវបណ្តាញអ្នកផ្គត់ផ្គង់អន្តរជាតិផ្នែកអាពាហ៍ពិពាហ៍ពីប្រទេសម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី ហុងកុង អូស្ត្រាលី និងញូវហ្ស៊ីលែនផងដែរ ។ អ្នកផ្គត់ផ្គង់ទាំងនេះគឺជាអ្នករៀបចំគម្រោងអាពាហ៍ពិពាហ៍របស់ The Sothea ដែលស្ថិតក្នុងទីរួមខេត្តសៀមរាប ហើយជាកន្លែងសម្រាកកម្សាន្តយ៉ាងប្រណីត ជាពិសេសផ្តល់នូវម្ហូបដ៏ពិសេសសម្រាប់អ្នកធ្វើដំណើរ ។ ក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ TWP នឹងមានសេវាកម្មជាកញ្ចប់ជាមួយកន្លែងសម្រាកកម្សាន្តជាន់ខ្ពស់នៅក្នុងតំបន់ដូចជា ប្រទេសថៃ ឡាវ វៀតណាម និងកោះបាលីផងដែរ ។

TWP ក៏ផ្តល់ការរៀបគម្រោងពិធីជប់លៀង និងការប្រារព្ធពិធីផ្សេងៗសម្រាប់ផ្នែកឯកជនផងដែរ៕ **ប៊ុន**